**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខៈ ០០៩/១៦ ស.ប.ក.ពបរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃសុក្រ ទី ២១ ខែ តុលា ឆ្នាំ ២០១៦

នៅព្រឹកថ្ងៃសុក្រទី២១ ខែតុលា ឆ្នាំ ២០១៦ វេលាម៉ោង៨ និង៤៥នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។**
**២- សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកា ទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។**
**៣- សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។**
**៤- បញ្ហាផ្សេងៗៈ**

### ១- សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ មាន ៦ជំពូក និង១៥ មាត្រា ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា កំពុងទទួលផលពីសុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថេរភាពនយោបាយ ដែលកើតចេញពីនយោបាយ **ឈ្នះ ឈ្នះ**។ ប្រការនេះបានអនុញ្ញាតឱ្យកម្ពុជាអាចសម្រេចបាននូវការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសការសម្រេចបាននូវបង្គោលចរមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ជាប្រទេសចំណូលមធ្យមកំរិតទាបនៅក្នុងឆ្នាំ២០១៥ កន្លងទៅ និងត្រៀមក្លាយជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ ក៏ដូចជាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត ទន្ទឹមនឹងការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស។

ថវិកាជាតិឆ្នាំ ២០១៧ ត្រូវបានគ្រោងក្នុងទឹកប្រាក់ ២០.១៨៤.៤៥៧ លានរៀលស្មើនឹង ២២, ៦៧% នៃផ.ស.ស គឺមានកំណើន ១៥,៦% ធៀបនឹងថវិកាឆ្នាំ ២០១៦។

ចំណាយចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០១៧ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតនៅកម្រិតចំនួន ១៣.០៥០.៦៨៦ លានរៀល ត្រូវជា ១៩,៦៦% នៃផ.ស.ស. គឺមានកំណើន ១៧,០% ធៀបទៅនឹងឆ្នាំ ២០១៦ ដែលក្នុងនោះ៖

**ចំណាយលើបន្ទុកបុគ្គលិក** រួមមាន៖ បៀវត្សរ៍មានជាអាទិ៍មូលដ្ឋានប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភ និវត្តជន លាភការ និងរង្វាន់ផ្សេងៗ សម្រាប់បុគ្គលិក ក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យាត្រូវបានគ្រោងចំនួន ៦.៨០៤.០៥៩ លានរៀល មានសមាមាត្រ ៥២,១៤% នៃចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវជា ៧,៦៤% នៃផ.ស.ស. គឺមានកំណើន ២០,៧% ធៀបនឹងថវិកាឆ្នាំ២០១៦។ ក្នុងនោះបានគ្រោង៖ (១)-ការដំឡើងប្រាក់បៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% (២)-ការដំឡើងប្រាក់ឧបត្ថម្ភប្រពន្ធ កូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយឱ្យកូនម្នាក់ចំនួន ១០.០០០រៀល ក្នុងមួយខែ និងប្រពន្ធចំនួន ១៥.០០០រៀល ក្នុងមួយខែ។ (៣)-ការដំឡើងប្រាក់បំណាច់មុខងារ។

**វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងចំនួន ៣.៣៣៨.៤០០ លានរៀល មានសមាមាត្រស្មើនឹង ២៥,៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវជា ៣,៧៥% នៃផ.ស.ស. គឺមានកំណើន ២០, ៤% ធៀបនឹងថវិកាឆ្នាំ២០១៦។

**វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងចំនួន ១.៣០៦.៣៦៧ លានរៀល មានសមាមាត្រស្មើនឹង ១០,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ១,៤៧% នៃផ.ស.ស. គឺមានកំណើន ១៣,១% ធៀបនឹងថវិកាឆ្នាំ២០១៦។

**វិស័យសង្គមកិច្ច** ត្រូវបានគ្រោងចំនួន ៤.៨៣៦.៤៩៨ លានរៀល មានសមាមាត្រស្មើនឹង ៣៧,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៥,៤៣% នៃផ.ស.ស. គឺមានកំណើន ១២,៧% ធៀបនឹងថវិកាឆ្នាំ២០១៦។

ថវិកាឆ្នាំ២០១៧ត្រូវបានគិតគូរ និងរៀបចំឡើងដើម្បីជានាចលនការនៃការកែទម្រង់ ព្រមទាំងតម្រង់ និងតម្រឹមគោលដៅនៃការកែទម្រង់ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងបានគិតគូរផងដែរទៅដល់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១៧ និងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិដែលអាចកើតមានឡើងជាយថាហេតុ និងផ្តល់ការឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស ទាំងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ក៏ដូចជាសម្រេចឱ្យបាននូវ *គោលដៅជាយុទ្ធសាស្ត្រ៤* ដូចមានចែងក្នុង *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣* ដើម្បី *កំណើនការងារសមធម៌* និង *ប្រសិទ្ធភាពនៅកម្ពុជា* ដែលជា *របៀបវារៈគោលនយោបាយសង្គមកិច្ច-សេដ្ឋកិច្ច* នៃ *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា* គឺ៖

ទី១.ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំ ប្រមាណ ៧% ប្រកបដោយចីរភាព និងបរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ

ទី២.បង្កើតការងារឱ្យបានកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជនតាមរយៈការវិនិយោគ

ទី៣.សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាជាង ១% ក្នុងមួយឆ្នាំក៏ដូចគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងទៅលើការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

ទី៤.បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

នៅក្នុងគោលដៅនេះរាជរដ្ឋាភិបាលបាន និងកំពុងជំរុញអនុវត្តយ៉ាងសកម្មនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ -២០២៥ ដែលជា *យុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ* សំដៅជំរុញពិពិធកម្មមូលដ្ឋានឧស្សាហកម្ម ឱ្យកាន់តែខ្លាំងក្លា មានភាពប្រកួតប្រជែង និងមានតម្លៃបន្ថែមកាន់តែខ្ពស់។

ក្នុងគោលដៅជួយសម្រួលជីវភាពរបស់មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ គ្រូពេទ្យ កងកម្លាំងប្រដាប់អាវុធ និងបងប្អូនកម្មករ បុគ្គលិក និយោជិក រដ្ឋាភិបាលក៏បានសម្រេចកែសម្រួលមាត្រា ៤៧ថ្មីនៃច្បាប់សារពើពន្ធ ដើម្បីដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សរ៍ជាប់ពន្ធឱ្យឡើងដល់ ១.០០០.០០០ រៀល និងដំឡើងកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើបៀវត្សរ៍ចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះរបស់មន្ត្រីរាជការក្នុងម្នាក់ៗពី ៧៥.០០០ រៀល ដល់ ១៥០.០០០ រៀលក្នុង ១ខែផងដែរ។

## ២- សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកា ទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ ២០១៥ រួមមាន៖ ចំណូលថវិកាជាតិ (ថវិកាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) ឆ្នាំ២០១៥ អនុវត្តបានចំនួន ១៧.០៦៦.៥៨០,៩ លានរៀល ស្មើនឹង ២៣,២៤% នៃ ផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ ៨,០% ។

ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០១៥ អនុវត្តបានចំនួន ១៤.៦៦០.១៤៧,១ លានរៀល ស្មើនឹង១៩,៩៧% នៃផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ ២.៥% ហើយបានកើនឡើង៩,២%ធៀបនឹងការអនុវត្តឆ្នាំ ២០១៤។

ការអនុវត្តថវិកាឆ្នាំ២០១៥ បានរួមចំណែកគាំទ្រដល់ការរក្សាបាននូវស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាពិសេសការសម្រេចបានកំណើនសេដ្ឋកិច្ច ៧,០% ដោយសារវឌ្ឍនភាពក្នុងការអនុវត្តការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។ កំណើនប្រកបដោយបរិយាប័ន្ននេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ការងារ ការលើកកម្ពស់ជីវភាព និងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ការអនុវត្តនូវប្រព័ន្ធសមាហរណកម្មមុខងារថ្មី ការបន្តដំឡើងបៀវត្សរ៍ជូនមន្ត្រីរាជការ និងវឌ្ឍនភាពនៃកំណែទម្រង់រដ្ឋបាលសាធារណៈស្របជាមួយការបន្តអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានរួមចំណែកដល់ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ។ ការអភិវឌ្ឍធនធានមនុស្សត្រូវបានលើកកម្ពស់គុណភាពក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការបង្កើនចំណាយថវិកាលើវិស័យអាទិភាពទាំងនោះ។ លំហថវិកាត្រូវបានពង្រីកជាលំដាប់តាមរយៈសមិទ្ធផលប្រមូលចំណូលល្អប្រសើរ និងការពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពផ្នែកចំណាយ។ លើសពីនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ ដើម្បីបន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព និងចីរភាពរយៈពេលវែង ដែលមានសារៈសំខាន់ដល់ការធានាស្ថិរភាពនិងនិរន្តរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៣- សេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។

ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ត្រូវបានចាត់ទុកជាអាទិភាពដ៏សំខាន់មួយ នៅក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។ ក្នុងគោលបំណងអភិវឌ្ឍវិស័យនេះ ផែនការយុទ្ធសាស្ត្ររយៈពេលវែង «ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០» ត្រូវបានរៀបចំឡើងជាលើកដំបូងនិងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០០១។ យុទ្ធសាស្ត្រនេះមានលក្ខណៈជាផែនការរំកិលដែលតម្រូវឱ្យមានការកែលម្អ និងធ្វើបច្ចុប្បន្នភាពតាមគ្រាដែលជាគោលការណ៍ គឺរៀងរាល់៥ឆ្នាំម្តង ដើម្បីលើកកម្ពស់ភាពប្រាកដនិយមនៃសកម្មភាពកែទម្រង់ និងសកម្មភាពអភិវឌ្ឍតាមរយៈជាអាទិ៍៖ ការកំណត់អាទិភាពការងារថ្មី និងការដាក់បញ្ចូលសកម្មភាពថ្មីៗ ផ្សេងទៀត ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការ និងការប្រែប្រួលជាក់ស្តែងនានា ស្របតាមបរិបទនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់កម្ពុជាក៏ដូចជាតម្រូវការក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាជំហានៗទៅក្នុងតំបន់។ កន្លងមករាជរដ្ឋាភិបាលធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះជាបន្តបន្ទាប់ចំនួន ២លើកទៅជា «យុទ្ធសាស្ត្រ**អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**» នៅក្នុងឆ្នាំ២០១១។

តាមរយៈការអនុវត្តប្រកបដោយភាពជាម្ចាស់យ៉ាងខ្ពស់នូវយុទ្ធសាស្ត្ររយៈពេលវែងនេះ នាពេលកន្លងមក វិស័យហិរញ្ញវត្ថុកម្ពុជា បាននិងកំពុងពង្រីកវិសាលភាព និងកំពុងមានការអភិវឌ្ឍឈានឡើងគួរឱ្យកត់សំគាល់។ ទន្ទឹមនេះ ក៏មានលេចចេញនូវតម្រូវការសេវាហិរញ្ញវត្ថុថ្មីៗរួមទាំងបញ្ហាប្រឈមថ្មីៗផងដែរ នៅក្នុងដំណើរការនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដែលតម្រូវឱ្យរាជ

រដ្ឋាភិបាលត្រូវធ្វើការកែសម្រួលនិងដាក់ចេញនូវគោលនយោបាយថ្មីៗ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរនោះ។

«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥» រៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធពិសេសធនាគារអភិវឌ្ឍអាស៊ី (ADB) គ្របដណ្តប់យ៉ាងទូលំទូលាយលើវិស័យហិរញ្ញវត្ថុ ដោយនៅក្នុងផ្នែកនីមួយៗបង្ហាញពីសមាសធាតុសំខាន់ៗចំនួន៤ គឺ៖ ទី១. ទិដ្ឋភាពទូទៅ ទី២.វឌ្ឍនភាព និងសមិទ្ធផល ទី៣.ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ និង ទី៤. យុទ្ធសាស្ត្រ និងផែនការអនាគត។

**៤- បញ្ហាផ្សេងៗ ៖**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងអំណរគុណចំពោះសមត្ថកិច្ច អាជ្ញាធរដែនដីខេត្តនានា ដែលរៀបចំបានល្អក្នុងឱកាសដែល សម្តេច បានចុះបំពេញភារកិច្ចនាពេលថ្មីៗនេះ និងបានណែនាំឱ្យថ្នាក់ដឹកនាំអគ្គបញ្ជាការកងយោធពលខេមរៈភូមិន្ទ រៀបចំចែកអាវរងារជូនកងកំលាំងប្រដាប់អាវុធនៅតាមព្រំដែនឱ្យទាន់រដូវរងារដែលចូលមកដល់។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១២ និង ០៥ នាទី។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី២១ ខែតុលា ឆ្នាំ២០១៦